# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៩ សសរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីកំណត់ព្រំប្រទល់ដីវត្តព្រំគីរីមរកត

• • • •

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីកំណត់ព្រំប្រទល់ដីវត្តព្រំគីរីមរកត ដែលស្ថិតនៅភូមិផ្សារព្រំ សង្កាត់ស្ទឹងកាច់ ខ័ណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ដែលមានសមាសភាព ដូចតទៅ :

| | |
|---|---|
| ១-តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២-តំណាងក្រសួងធម្មការ និងសាសនា | អនុប្រធាន |
| ៣-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤-តំណាងសាលាក្រុងប៉ៃលិន | សមាជិក |
| ៥-តំណាងវត្តព្រំគីរីមរកត | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ÷

-ចុះអង្កេតវង្គបាលលើផ្ទៃដីកំណត់ព្រំប្រទល់ដីវត្តព្រំគីរីមរកត

-ស្រាវជ្រាវស្រង់ស្ថិតិផ្ទៃដីវត្តព្រំគីរីមរកត ដែលត្រូវជាសម្បត្តិរដ្ឋអោយបានពិតប្រាកដ

-លើកវិធានការដោះស្រាយ និងសំណូមពរក្នុងការគ្រប់គ្រងដីវត្តព្រំគីរីមរកត

-ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិការបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ អភិបាលក្រុងប៉ៃលិន និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-ឯកសារ- កាលប្បវត្តិ